ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

និយ័តករគណនេយ្យនិងសវនកម្ម
លេខ ០៤៧/២៤ .......ន. គ. ស/ សាក.លា.

# សេចក្តីជូនដំណឹង
## ស្តីពី
## ការចូលជាធរមាននៃ ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ លេខ ១៨ "ការដាក់បង្ហាញ និងការលាតត្រដាងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ" ចេញផ្សាយដោយក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិ

និយ័តករគណនេយ្យនិងសវនកម្ម មានកិត្តិយសសូមជម្រាបជូនដំណឹងដល់គ្រប់ម្ចាស់សហគ្រាស ប្រធានអង្គភាពមិនស្វែងរកប្រាក់ចំណេញ គណនេយ្យករ សវនករ និងសាធារណជនទូទៅ ឱ្យបានជ្រាបថា÷ នាថ្ងៃទី០៩ ខែមេសា ឆ្នាំ២០២៤ ក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិ (International Accounting Standards Board) ដែលជាស្ថាប័នឯករាជ្យក្នុងការអភិវឌ្ឍ និងអនុម័តលើស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ បានចេញផ្សាយនូវស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ លេខ ១៨ "ការដាក់បង្ហាញ និងការលាតត្រដាងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ" ដែលនឹងជំនួសស្តង់ដាគណនេយ្យអន្តរជាតិ លេខ ១ "ការដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុ"។

ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ លេខ ១៨ "ការដាក់បង្ហាញ និងការលាតត្រដាងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ" នឹងចូលជាធរមានចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២៧ តទៅ ជាមួយនឹងការលើកទឹកចិត្តឱ្យអនុវត្តមុនកាលបរិច្ឆេទកំណត់នេះបាន។

សម្រាប់ព័ត៌មានលម្អិត សូមចូលទៅកាន់គេហទំព័ររបស់និយ័តករ : www.acar.gov.kh។

អាស្រ័យហេតុនេះ សូមម្ចាស់សហគ្រាស ប្រធានអង្គភាពមិនស្វែងរកប្រាក់ចំណេញ គណនេយ្យករ និងសវនករ ជ្រាបជាព័ត៌មាន និងត្រូវត្រៀមលក្ខណៈឱ្យបានរួចរាល់សម្រាប់ការអនុវត្តស្តង់ដាថ្មីនេះនៅកម្ពុជាទៅតាមពេលវេលាកំណត់ខាងលើ។

ថ្ងៃព្រហស្បតិ៍ ៤ រោច ខែ ចេត្រ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៧
រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០២៤
អគ្គនាយក

ឡូ ចារិន